ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មិនា ២០០៦ / March 2006

កញ្ញា អ៊ុច ចំន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុត្ថា / **Mr. Hing Vutha**

លោក ភីម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ

ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

វិនិយោគឯកជនគិតជាទ្រព្យសកម្មជាប់លាប់ដែលបានអនុម័ត មានជិតដល់ ១.០៩៥លានដុល្លារនៅឆ្នាំ២០០៥ (ប្រហែល៤ដងខ្ពស់ជាងឆ្នាំ២០០៤) ក្នុងនេះវិស័យឧស្សាហកម្មមាន ៩១២,៦លានដុល្លារ (ធៀបនឹង ១៧១លានដុល្លារនៅឆ្នាំ២០០៤), វិស័យសេវាកម្មមាន ១៥៥,៥លានដុល្លារ (៩១,៨លានដុល្លារនៅឆ្នាំមុន) និង កសិកម្ម ២៦,៨លានដុល្លារ (កើនជាងពីរដងពីកំរិត ១២,៣លានដុល្លារនៅឆ្នាំ២០០៤) ។

The value of registered fixed assets of private investment project approvals amounted to nearly $1,095 million in 2005, about four times higher than in 2004. Investments in the industry sector in 2005 accounted for 83 percent ($912.6 million) of total investments, compared with around $171 million in 2004. Investments in the service sector were valued at $155.5 million in 2005, up from $91.8 million one year earlier. During the same period, the value of investment project approvals in the agricultural sector slightly more than doubled, from $12.3 million to $26.8 million.

**Private Investment Approvals by Sectors**
(US$ million)




*Note: Latest data available are for December 2005.*
Including expansion project approvals.
Source: Council for the Development of Cambodia

តាមទិន្នន័យបណ្ដោះអាសន្នពីក្រសួងទេសចរណ៍ នៅឆ្នាំ២០០៥ មានភ្ញៀវបរទេសមកដល់កម្ពុជា ១.៤១៣.៥៤៤នាក់ រឺ ៣៤%ច្រើនជាងឆ្នាំមុន (រឺ ១៣%ច្រើនជាងការព្យាករណ៍របស់ក្រសួងទេសចរណ៍) ក្នុងនេះភ្ញៀវមកដល់តាមផ្លូវអាកាសមាន ៨៥៥.៨៥០នាក់ (កើន ៣៦,៧%) រីឯតាមផ្លូវគោកនិងទឹក មាន ៥៥៧.៦៩៤នាក់ (កើន ៣០%) ។

According to the provisional data from the Ministry of Tourism, the number of foreign visitor arrivals to Cambodia totalled 1,413,544 persons in 2005, 34 percent higher than in the previous year. Of this, a total of 855,850 persons were arrivals by air, an increase of 36.7 percent compared to 2004. Arrivals by land and boat rose by 30 percent to 557,694 persons. The total number of foreign visitors in 2005 was 13 percent higher than the number forecasted by the Ministry of Tourism.

**Foreign Visitor Arrivals to Cambodia by Air, Land and Boat** (thousand persons)




*Note: Latest data available are for December 2005.*
Source: Ministry of Tourism

តំលៃគំរោងសាងសង់ដែលបានអនុម័តនៅភ្នំពេញ កើន ៣៦,២% ពីកំរិត ២៦៣,៥លានដុល្លារនៅឆ្នាំ២០០៤ ដល់ ៣៥៨,៨លានដុល្លារនៅឆ្នាំ២០០៥ ក្នុងនេះគំរោងសាងសង់ផ្ទះល្វែងមាន ២០៤,២លានដុល្លារ (កើន ២១,៨%) គំរោងសាងសង់ភូមិគ្រឹះនិងផ្ទះ មាន ៤៥,៥លានដុល្លារ (កើន ៥០,២%) និងគំរោងសំណង់ផ្សេងទៀតមាន ១០៩,១លានដុល្លារ (កើន ៦៦,៣%) ។

Construction project approvals in Phnom Penh in 2005 were valued at $358.8 million, rising by 36.2 percent from $263.5 million in 2004. Of this, about 57 percent ($204.2 million) were flat construction projects, a 21.8 percent increase from 2004. The value of villa and house construction approvals rose by 50.2 percent to $45.5 million, and other construction projects increased by 66.3 percent to $109.1 million.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for December 2005.*
Source: Department of Cadastre and Geography, Phnom Penh Municipality.

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែកុម្ភៈ ថ្លៃមធ្យមនៃសាំង និងម៉ាស៊ូតនៅភ្នំពេញកើនឡើង ក្រោយបាន ថយចុះអស់ ៣ខែជាប់គ្នា ។ សាំងលក់ថ្លៃ ៣.៧៦៧,៦រៀល/លីត្រ នៅខែកុម្ភៈ រឺ កើន ១,៩%ធៀបនឹងខែមុន ឯម៉ាស៊ូតលក់ថ្លៃ ២.៨៧៦រៀល/លីត្រ រឺកើន ០,៥% ។

In February, the average gasoline and diesel prices in Phnom Penh rose, after falling for three consecutive months. The price of gasoline was 3,767.6 riels/litre in February, a 1.9 percent increase compared to the preceding month. At the same time, the price of diesel was 2,876 riels/litre, an increase of 0.5 percent.

## Price of Gasoline and Diesel Oil in Phnom Penh

(Riels per litre)




Sources: CDRI and National Institute of Statistics

នៅខែមករា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅនៅភ្នំពេញ កើនបន្តិចត្រឹម ០,១% ធៀបនឹងខែធ្នូ ២០០៥។ សន្ទស្សន៍ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើនប្រហែល ១% ហើយសន្ទស្សន៍ម្ហូបអាហារធ្លាក់ចុះប្រហែល ០,២% ។ ធៀបនឹងខែមករា ២០០៥ ថ្លៃទំនិញប្រើប្រាស់ទូទៅ កើន ៦,៣% ឯថ្លៃម្ហូបអាហារ និង ដឹកជញ្ជូន/ទូរគមនាគមន៍ កើន ១០,៨% និង ១០,២% រៀងៗគ្នា ។

The overall consumer price index in Phnom Penh in January 2006 rose slightly by 0.1 percent compared to December 2005. The price index for transportation and communication items grew by about 1 percent, while the food price index fell by around 0.2 percent. Compared to January last year, overall price soared by 6.3 percent. In the meantime, prices of food and transportation and communication rose at a rate of 10.8 percent and 10.2 percent, respectively.

## Consumer Price Index

(July–December 2000=100)




*Note: Latest data available are for January 2006*
Source: National Institute of Statistics

យោងតាមធនាគារជាតិនៃកម្ពុជា នៅឆ្នាំ២០០៥ អត្រាការប្រាក់មធ្យមលើកំចីរយៈ១២ខែ របស់ធនាគារពាណិជ្ជ (ជារៀល និងដុល្លារ) បានថយចុះបើធៀបនឹងឆ្នាំមុន ។ ចំពោះកំចីជារៀល វាមានកំរិត ១៨,៦% គឺប្រហែលគ្នានឹងឆ្នាំមុន ហើយសំរាប់កំចីជាដុល្លារវាចុះដល់ ១៦,២% ធៀបនឹង ១៦,៧%នៅឆ្នាំ២០០៤ ។

According to the National Bank of Cambodia, average interest rates on 12-month loans of the commercial banks (both in Riel and in US dollar) declined in 2005, compared to the previous year. The 12-month lending rate in Riels was 18.6 percent in 2005, similar to the previous year, when it was 18.7 percent. The US dollar 12-month lending rate stood at an average rate of 16.2 percent in 2005, down from about 16.7 percent in 2004.

## Cambodia's Interest Rate on 12-Month Loan

(% per annum, as of December)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ

# Exchange Rate and Monetary Developments

នៅខែកុម្ភៈ ប្រាក់រៀលកម្ពុជាបន្តឡើងថ្លៃទល់នឹងដុល្លារUS ដល់ ៤.០៨៧ រៀល/ដុល្លារ រឺឡើងថ្លៃ ០,៣%ធៀបនឹងខែមករា (៤.១០០រៀល/ដុល្លារ) ប៉ុន្តែបានចុះថ្លៃ ១,២% ធៀបនឹងខែកុម្ភៈ ២០០៥ (៤.០៤០រៀល/ដុល្លារ ។

The monthly average market rate between the Cambodian riel and US dollar continued to appreciate in February. One dollar was traded at 4,087 riels in February, an appreciation of 0.3 percent from around 4,100 riels/dollar in January, but a depreciation of 1.2 percent from 4,040 riels/dollar in February 2005.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

នៅខែកុម្ភៈ ប្រាក់រៀលបានចុះថ្លៃទល់នឹងប្រាក់បាតថៃ ដល់ ១០៣,១ រៀល/បាត រឺចុះថ្លៃ ០,៦%ធៀបនឹងខែមុន (១០២,៥រៀល/បាត) ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលប្តូរបាន ២៥,៣រៀល/១០០ដុង នៅខែកុម្ភៈ រឺឡើងថ្លៃ ០,៩%ធៀបនឹងខែមករា ។

The market rate between the riel and the Thai baht in February was 103.1 riels/baht, depreciating by 0.6 percent from 102.5 riels/baht in the preceding month. Against the Vietnamese dong, the rate averaged at 25.3 riels per 100 dong in February, a 0.9 percent appreciation from January.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI

នៅចុងខែធ្នូ ២០០៥ រូបិយវត្ថុទូទៅថយចុះដល់ ៥.០២៤,៩ពាន់លានរៀល រឺថយចុះ ១៦%ធៀបនឹងពេលដូចគ្នាឆ្នាំមុន។ ក្នុងនេះប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើន១៤% ដល់ ៨៧២,១លានដុល្លារ( ៣.៥៨៩,៤ពាន់លានរៀល) ធៀបនឹង ៧៦៣,៨លានដុល្លារ (៣.០៧៩,១ពាន់លានរៀល) នៅឆ្នាំមុន។ ប្រាក់រៀលកំពុងចរាចរ កើន ១៥% ដល់ ១.២៨២,១ពាន់លានរៀលនៅឆ្នាំ២០០៥ និងប្រាក់រៀលផ្ញើនៅធនាគារ កើន ១៣,២% ដល់ ១៥៣,៤ ពាន់លានរៀល ។

At the end of December 2005, total liquidity amounted to 5,024.9 billion riels, marking a decline of about 16 percent compared to the same time last year. Foreign currency deposits rose by 14 percent to $872.1 million (3,589.4 billion riels) in 2005, up from $763.8 million (3,079.1 billion riels) in 2004. The amount of riels in circulation expanded by 15 percent to 1,282.1 billion riels in 2005, while the amount of riels in bank deposits grew by 13.2 percent to 153.4 billion riels.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for December 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅឆ្នាំ២០០៥ ការនាំចេញសរុបរបស់កម្ពុជាមាន ២.៣៥២,៨លានដុល្លារ រឺ ១១,៦%ច្រើនជាងឆ្នាំ២០០៤ ។ ការនាំចេញសំលៀកបំពាក់កើន ១១,២% ដល់ ២.២៥៣,៣លានដុល្លារ ។ ក្នុងចំណោមផលិតផលកសិកម្មនាំចេញចំបង៣បីមុខ ការនាំចេញអង្ករកើន ៤៣,៧% ដល់ ២,៦លានដុល្លារ, រីឯការនាំចេញកៅស៊ូ និង ត្រី ថយចុះ ៤,២% ដល់ ៣៦,៧លានដុល្លារ, និង ៥,៨% ដល់ ១០លានដុល្លារ រៀងៗគ្នា ។

Cambodia's total exports in 2005 amounted to $2,352.8 million, 11.6 percent more than in 2004. Garment exports grew by 11.2 percent to $2,253.3 million. Among the three major agricultural product exports, rice exports rose by 43.7 percent to $2.6 million, while rubber and fish exports declined by 4.2 percent to $36.7 million and by 5.8 percent to $10 million, respectively.

## Cambodia's Main Exports

(US$ million)




*Note: Latest data available are for December 2005.*
Source: Customs and Excise Department

នៅឆ្នាំ២០០៥ ការនាំចូលសំភារៈសំណង់ (ស៊ីម៉ង់ត៍និងដែក) សរុបមាន ២៦៨,៧ពាន់លានរៀល ឯការនាំចូលបារីមាន ៣២៦,៤ពាន់លានរៀល ។ ធៀបនឹងឆ្នាំ ២០០៤ ការនាំចូលសំភារៈសំណង់ កើន ១៤,៣% ក្នុងនេះ ស៊ីម៉ង់ត៍ កើន ១៤,៥% ដល់ ១៨១,៧ពាន់លានរៀល និងដែក កើន ១៤,១% ដល់ ៨៦,៩ ពាន់លានរៀល។ ក្នុងពេលដដែល ការនាំចូលបារីថយចុះបន្តិចអស់ 0,១%។

In 2005, the total value of construction material imports, cement and steel, amounted to 268.7 billion riels, while cigarette imports accounted for 326.4 billion riels. Compared to 2004, imports of construction materials jumped by 14.3 percent, of which cement rose by 14.5 percent to 181.7 billion riels, and steel was up by 14.1 percent to 86.9 billion riels. Meanwhile, imports of cigarette were down slightly by 0.1 percent.

## Imports of Cigarettes and Construction Materials

(billion riels)




*Note: Latest data available are for December 2005.*
*(Excluding public sector imports)*
Source: Customs and Excise Department

នៅឆ្នាំ២០០៥ កម្ពុជានាំចូលសាំងមានតំលៃសរុប ១៦៣,៨ពាន់លានរៀល (កើន ៣៦,៥%ធៀបនឹងឆ្នាំមុន) និងម៉ាស៊ូត ៣៦៥,៦ពាន់លានរៀល (ថយចុះ ១៥,៨%) ។ យោងតាមទិន្នន័យរបស់ទីចាត់ការគយនិងរដ្ឋាករ ចំនួលពន្ធប្រមូលបានពីការនាំចូលសាំង និងម៉ាស៊ូត នៅឆ្នាំ២០០៥ គឺ ១៨១,៦ពាន់លានរៀល (កើន ២២,៥%ធៀបនឹងឆ្នាំមុន) និង ១៩១,៧ ពាន់លានរៀល (ថយចុះ ២0%ធៀបនឹងឆ្នាំ២០០៤) រៀងគ្នា ។

Cambodia imported a total of 163.8 billion riels worth of gasoline and 365.6 billion riels of diesel in 2005. The value of gasoline imports rose by 36.5 percent from the previous year, while diesel imports decreased by 15.8 percent. Based on data recorded by the Customs and Excise Department, tax revenue collected from gasoline and diesel imports in 2005 was 181.6 billion riels and 191.7 billion riels, marking an increase of 22.5 percent and a decrease of 20 percent, respectively, from 2004.

## Imports of Petroleum Products

(billion riels)




*Note: Latest data available are for December 2005.*
*(Excluding public sector imports)*
Source: Customs and Excise Department

# ប្រភព និងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

ខេត្តព្រះវិហារដែលមាន ៧ស្រុក (៤៩ឃុំ និង ៣១៧សមាជិកក្រុមប្រឹក្សាឃុំ) ទទួលបានមូលនិធិឃុំ/សង្កាត់ឆ្នាំ២០០៥ ចំនួន ១.០៨ពាន់លានរៀល សំរាប់សកម្មភាពអភិវឌ្ឍន៍ និង០.៥៣ពាន់លានសំរាប់ប្រតិបត្តិការរដ្ឋបាល ។ ធៀបនឹងឆ្នាំ២០០៤ មូលនិធិអភិវឌ្ឍន៍កើន ២៣% ហើយ មូលនិធិរដ្ឋបាល កើន ៧.៨% ។

Preah Vihear province, which consists of seven districts (49 communes and 317 councilors), received about 1.08 billion riels for development activities and 0.53 billion riels for administrative operations from commune/ sangkat funds in 2005. Compared to 2004, development funds increased by 23 percent, while administrative funds rose by 7.8 percent.

**2005 Commune/Sangkat Fund Allocation to Preah Vihear Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

សំរាប់ខេត្តរតនគិរី (៩ស្រុក, ៤៩ឃុំ និង ២៥១ សមាជិកក្រុមប្រឹក្សាឃុំ) មូលនិធិអភិវឌ្ឍន៍នៅក្នុងមូលនិធិឃុំ/សង្កាត់ឆ្នាំ២០០៥ មាន ១.០៧ពាន់លានរៀល រឺកើន ២៤.៣% ធៀបនឹងឆ្នាំ២០០៤ ។ រីឯមូលនិធិសំរាប់ប្រតិបត្តិការរដ្ឋបាល មាន ០.៤៥ពាន់លានរៀល រឺកើន ៧.៣% ។

Development funds from the commune/sangkat funds allocated to Ratanakiri province (9 districts, 49 communes and 251 councilors) were 1.07 billion riels in 2005, an increase of 24.3 percent from 2004. The funds for administration was 0.45 billion riels, marking a 7.3 percent rise.

**2005 Commune/Sangkat Fund Allocation to Ratanakiri Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ក្នុងមូលនិធិឃុំ/សង្កាត់ឆ្នាំ២០០៥ សំរាប់ខេត្តកោះកុង (៨ស្រុក ៣៣ឃុំ និង ១៨៧សមាជិកក្រុមប្រឹក្សាឃុំ) មាន ០.៧៧ពាន់លានរៀល សំរាប់សកម្មភាពអភិវឌ្ឍន៍ និង ០.៣២ពាន់លានរៀល សំរាប់ខាងរដ្ឋបាល ។ បើធៀបនឹងឆ្នាំ២០០៤ ថវិកាទាំងពីរនេះ កើនបាន ២០.២% និង ៧.៧% រៀងគ្នា ។

A total of 0.77 billion riels and 0.32 billion riels from commune/sangkat fund in 2005 was provided for development and administrative activities in Koh Kong province, which has 8 districts, 33 communes, and 187 councilors. Fund for both activities were up by 20.2 percent and 7.7 percent from previous year, respectively.

**2005 Commune/Sangkat Fund Allocation to Koh Kong Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ត្រឹមខែវិច្ឆិកា២០០៥ ប្រតិបត្តិការថវិកាចរន្តកម្ពុជា មានអតិរេក ៦៤៨,៨ ពាន់លានរៀល ធៀបនឹង អតិរេកប្រហែល ៦១៣ពាន់លានរៀល ក្នុងកំឡុងពេលដូចគ្នាឆ្នាំ២០០៤ និង អតិរេក ៣៦១,៦ពាន់លានរៀល ក្នុងឆ្នាំ២០០៤ ទាំងមូល ។

As of November 2005, the Cambodia’s current budget operation exhibited a surplus of 648.8 billion riels, compared with a surplus of about 613 billion riels at the same time 2004, and with a 361.6 billion riels surplus in 2004.

**Current Budget Operations**
(billion riels)




Note: **up to November 2005.*
Source: *Monthly Bulletin of Statistics (MEF)*

ចំណូលថវិកាចរន្តមានសរុប ២.១២៤,៥ពាន់លានរៀល ក្នុងរយៈពេលពីខែមករា-វិច្ឆិកា២០០៥ (៩៣%នៃផែនការ) រីកើន ២៤%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (១.៧១៣ពាន់លានរៀល) ។ ក្នុងនេះ ចំនូលពន្ធក្នុងស្រុកកើន ៤៦% ដល់ ៥០៩,៣ពាន់លានរៀល, ចំនូលមិនមែនពន្ធកើន ២០% ដល់ ៤៧៦,២ពាន់លានរៀល និងចំនូលពន្ធនាំចេញ-នាំចូល កើន ១៧,៨% ដល់ ១.១៣៩ពាន់លានរៀល ។

Current budget revenue totalled to 2,124.5 billion riels during January-November 2005, achieving 93 percent of the target. Compared to the same period one year earlier, it rose by 24 percent, from 1,713 billion riels. Revenue from domestic taxes increased by 46 percent to 509.3 billion riels, followed by non-tax revenue which was up by 20 percent to 476.2 billion riels. Also, revenue from import and export taxes swelled by 17.8 percent to 1,139 billion riels.

**Current Budget Revenue**
(billion riels)




Note: ** up to November 2005.*
Source: Monthly Bulletin of Statistics (MEF)

ពីខែមករា-វិច្ឆិកា ២០០៥ ចំណាយថវិកាចរន្តឡើងដល់ ១.៤៧៥,៨ពាន់-លានរៀល (៧៤%នៃផែនការ) រីកើន ៣៤,២%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០០៤ ។ ក្នុងនេះចំនាយចរន្តចំបងៗទាំង៥ប្រភេទ កើនឡើងទាំងអស់ និងនាំមុខដោយចំនាយរដ្ឋបាលទូទៅ ។

Current budget expenditures amounted to 1,475.8 billion riels from January-November 2005. It reached 74 percent of its target and increased by 34.2 percent from the same period in 2004. All five major categories of the government current spending rose during the same period, mainly lead by general administrative expenditure.

**Current Budget Expenditure**
(billion riels)




Note: ** up to November 2005.*
Source: Monthly Bulletin of Statistics (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែធ្នូ ២០០៥ ការនាំចេញទំនិញពី US តំបន់អឺរ៉ូ និងជប៉ុន កើនឡើង ។ ការនាំចេញពី US កើន ២% ធៀបនឹងខែមុន ដល់ ៧៩,០២ពាន់លានដុល្លារ ដោយសារកំនើនការនាំចេញទំនិញជាមូលធន ទំនិញប្រើប្រាស់ និងសំភារៈឧស្សាហកម្មសំខាន់ៗ ។ ទំនិញនាំចេញពីតំបន់អឺរ៉ូ កើន ១% ធៀបនឹងខែមុន ដល់ ១២៩,៤ពាន់លានដុល្លារ ឯនៅជប៉ុនវាកើនដល់ ៥៣,០៧ពាន់លានដុល្លារ ធៀបនឹង ៥០,៦៩ពាន់លានដុល្លារ នៅខែវិច្ឆិកា ។

In December 2005, the exports of goods from US, Eurozone and Japan increased. US exports rose by 2 percent over the previous month, from US$ 77.36 billion to US$ 79.02 billion. The increase in exports of goods was mostly accounted for by increases in capital goods, consumer goods and industrial supplies and materials. The Eurozone exports of goods rose by 1 percent from the previous month from US$ 127.88 billion to US$ 129.4 billion. Japan's goods exports in December also registered positive growth from the previous month to US$ 53.07 billion, up from US$ 50.69 billion in November.

**Goods Exports by the US, Eurozone and Japan**
(US$ billion)




Source: BEA, Eurostat and OECD

នៅខែធ្នូ ២០០៥ ការនាំចេញទំនិញរបស់កូរ៉េខាងត្បូងថយចុះ រីឯរបស់តៃវ៉ាន់នៅថេរ ។ ទំនិញនាំចេញពីកូរ៉េខាងត្បូងថយចុះ ១% ធៀបនឹងខែមុនមកត្រឹម ២៥,៦៣ពាន់លានដុល្លារ ដោយសារកំនើនអវិជ្ជមាននៃវត្ថុធាតុដើម ប្រេងឥន្ធនៈ ភេសជ្ជៈ ម៉ាស៊ីន និងសំភារៈដឹកជញ្ជូន ។ ទំនិញនាំចេញរបស់តៃវ៉ាន់នៅថេរត្រឹម ១៧,១៧ពាន់លានដុល្លារ ។

In December 2005, goods exports from South Korea decreased, while goods exports from Taiwan remained steady. South Korea exports of goods decreased by 1 percent from the previous month to US$ 25.63 billion. Crude materials, mineral fuels, beverages, and machinery and transport equipments registered negative growth compared to the previous month. Taiwan's exports in December remained the same as the previous month at US$17.17 billion.

**Goods Exports by South Korea and Taiwan**
(US$ billion)




Source: National Statistics Department of respective countries

នៅខែធ្នូ ២០០៥ ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២,៤៩ពាន់លានដុល្លារ ធៀបនឹងអតិរេក ២,២៩ពាន់លានដុល្លារ នៅខែវិច្ឆិកា ។ ការនាំចេញសរុបកើន ២៦% ធៀបនឹងខែមុនដល់ ១៣,០៣ពាន់លានដុល្លារ ឯការនាំចូលសរុបកើន ១៥% ដល់ ១០,៥៥ពាន់លានដុល្លារ ។ ផលិតផលអគ្គិសនី និងអេឡិចត្រូនិក តំណាងឱ្យ ៥០,១%នៃការនាំចេញ រីឯ ទំនិញពាក់កណ្ដាលសំរេច និងទំនិញជាមូលធន គឺជាមុខទំនិញចំបងក្នុងការនាំចូលសរុប ។

In December 2005, Malaysia recorded a trade surplus of US$2.49 billion, compared to a surplus of US$2.29 billion in November. Total exports in December rose by 26 percent compared to the previous month to US$ 13.03 billion, while total imports rose by 15 percent to US$ 10.55 billion. Electrical and electronic products, which accounted for 50.1 percent of exports continued to be the largest contributor of total exports. Intermediate and capital goods are the major contributor to total imports.

**Malaysia's External Trade**
(US$ billion)




Source: National Statistics Department of respective countries

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា
# Inflation rates in Selected Economic Partners of Cambodia

អត្រាអតិផរណាប្រចាំឆ្នាំ ថយចុះបន្តិចនៅខែធ្នូ ដល់ ២.២% (២.៤% នៅខែវិច្ឆិកា) ដោយសារការថយចុះអត្រាឡើងថ្លៃប្រចាំឆ្នាំនៃម្ហូបអាហារកែច្នៃ ។ ក្នុងពេលដដែល អត្រាអតិផរណាទំនិញប្រើប្រាស់មានកំរិត ៣.៤% នៅ US និង -០.១% នៅជប៉ុន ។

The overall euro area year-on-year inflation rate decreased slightly in December to 2.2 percent, down from 2.4 percent in November. This decline was due mainly to a decline in the annual rate of growth in processed food prices. During the same period, the consumer inflation rate ran at 3.4 percent in the U.S and -0.1 percent in the Japan.

### Inflation Rate in the US, Europe and Japan
(percentage change over the previous year)




*Note: The latest data available are for Dec. 2005.*
Sources: IMF and the *Economist* (Feb, 4-10, 2006)

នៅហុងកុង ថ្លៃទំនិញប្រើប្រាស់ទូទៅ កើន ១.៨% នៅខែធ្នូ បើធៀបនឹងកាលពី១ឆ្នាំមុន (កំនើន ១.៧%នៅខែវិច្ឆិកា) ដោយសារជាសំខាន់កំនើនថ្លៃឈ្នួលផ្ទះឯកជន និងថ្លៃគ្រឿងអលង្ការ ។ ក្នុងពេលដដែល អតិផរណាថ្លៃទំនិញប្រើប្រាស់ កើនដល់ ១.៦% នៅចិន និង ២.៤% នៅកូរ៉េខាងត្បូង ។

In Hong Kong, overall consumer prices rose by 1.8 percent in December 2005 over the previous year, slightly larger than the 1.7 percent increase in November. The larger year-on-year increase was mainly attributable to the enlarged increases in private housing rentals as well as the prices of jewellery. During the same period, the consumer inflation accelerated to 1.6 percent in China and edged up to 2.4 percent in South Korea.

### Inflation Rate in China, Hong Kong and S. Korea
(percentage change over the previous year)




*Note: The latest data available are for Dec. 2005.*
Sources: IMF and the *Economist* (Feb, 4-10, 2006)

នៅខែធ្នូ អតិផរណានៅសិង្ហបុរី កើន ១.៣%ធៀបនឹងកាលពី១ឆ្នាំមុន។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី រឿងនេះបង្ហាញជាសំខាន់ពីការឡើងថ្លៃអាហារ សំលៀកបំពាក់ ស្បែកជើង ការអប់រំ សំភារៈការិយាល័យ ចំណាយស្នាក់នៅ ថែទាំសុខភាព និងលំហែកំសាន្ត ។ ក្នុងពេលដដែល អត្រាអតិផរណាប្រចាំឆ្នាំលើទំនិញប្រើប្រាស់ នៅថេរ នៅម៉ាឡេស៊ី និងថយចុះទាបជាងខែមុនបន្តិចមកត្រឹម ៥.៨% នៅថៃ ។

Singapore’s inflation rose by 1.3 percent in December 2005 compared to the same month a year ago. According to the Department of Statistics of Singapore, this largely reflected dearer costs of food, clothing and footwear, education and stationary, housing, healthcare and recreation. Meanwhile, the annualized rate of consumer inflation was flat in Malaysia and slightly dropped from the previous month to 5.8 percent in Thailand.

### Inflation Rate in Selected ASEAN Countries
(percentage change over the previous year)




*Note: The latest data available are for Dec. 2005.*
Sources: IMF and the *Economist* (Feb, 4-10, 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rate in the World Markets

នៅខែកុម្ភៈ ដុល្លារUS ឡើងថ្លៃទល់នឹងរូបិយវត្ថុចំបងៗ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៨៤អឺរ៉ូ/ដុល្លារ រឺឡើងថ្លៃ ១,២%ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនវាប្តូរបាន ១១៨,២យ៉េន/ដុល្លារ ធៀបនឹង ១១៥,៦យ៉េន/ដុល្លារ នៅខែមុន ។ ដុល្លារបានឡើងថ្លៃដោយសារមានការវាយស្មានថា អត្រាការប្រាក់នៅUS ដែលអំណោយផលជាងនៅអឺរ៉ុប និងជប៉ុន នឹងបន្តទាក់ទាញ វិនិយោគិនឱ្យទិញទ្រព្យសកម្មនៅUS ។

In February, the US dollar rallied against major currencies. Against the euro, it was traded at 0.84 euro/USD, about 1.2 percent appreciation over the previous month. Against the yen, it was exchanged at 118.2 JPY/USD, up from 115.6 JPY/USD a month earlier. The dollar strengthened on speculation that the U.S. interest rate advantage over Europe and Japan would continue to attract investors to U.S. assets.

**Euro and Japanese Yen Against the US Dollar**




*Note: Data are up to 23 Feb. 2006*
Sources: The Federal Reserve Bank of New York

នៅខែកុម្ភៈ ប្រាក់វ៉ុនកូរ៉េខាងត្បូងបន្តឡើងថ្លៃបាន៤ខែជាប់គ្នា ទល់នឹងដុល្លារUS ដោយប្តូរបាន ៩៦៩,១៦វ៉ុន/ដុល្លារUS ធៀបនឹង ៩៨៣,៣៦វ៉ុន/ដុល្លារUS នៅខែមុន ។ ប្រាក់វ៉ុនឡើងថ្លៃដោយសារមានការវាយស្មានថា ធនាគារកណ្តាលកូរ៉េខាងត្បូងនឹងទិញដុល្លារចូល ដើម្បីព្យាយាមពន្យឺតការឡើងថ្លៃប្រាក់វ៉ុន ។ ក្នុងពេលដដែល ដុល្លារហុងកុងចុះថ្លៃបន្តិចទល់នឹងដុលារUS ដោយប្តូរបាន ៧,៧៦ដុល្លារហុងកុង/ដុលារUS ។

In February, the South Korean won continued to rise against the US dollar for a fourth consecutive month, trading at 969.16 from 983.36 a month earlier. The won was strengthened on speculation South Korean central bank will buy dollars as an attempt to slow the Korean currency's appreciation instead of reversing trend. During the same period, the Hong Kong dollar slightly dropped against its US counterpart trading at 7.76.

**South Korean Won and Hong Kong Dollar Against the US Dollar**




*Note: Data are up to 23 Feb. 2006*
*Sources: The Federal Reserve Bank of New York*

នៅខែកុម្ភៈ ដុល្លារសិង្ហបុរីប្តូរឡើងថ្លៃបន្តិចទៀត(ឡើង៣ខែជាប់គ្នា) ដោយប្តូរបាន ១,៦៣ដុល្លារសិង្ហបុរី/ដុល្លារUS ។ ក្នុងពេលដដែលប្រាក់បាតថៃប្តូរបាន ៣៩,៣៧បាត/ដុល្លារUS រឺឡើងថ្លៃបន្តិចធៀបនឹងខែមុន (៣៩,៦០បាត/ដុល្លារUS) ។ រូបិយវត្ថុអាស៊ីនានាបានឡើងថ្លៃ ពីព្រោះទុនបរទេសកំពុងហូរចូលទីផ្សារហ៊ុនក្នុងតំបន់ ដោយសារវិនិយោគិនមានសុទិដ្ឋិនិយមថា កំនើនសេដ្ឋកិច្ចក្នុងតំបន់នេះនឹងស្ទុះឡើងទៀត ។

In February, the Singapore dollar was traded at 1.63 SGD/USD, slightly advanced against the US dollar, for the third month in row. Meanwhile, the Thai baht was traded at 39.37 baht/USD, slightly gained from 39.60 baht/USD a month earlier. Asian currencies strengthened as overseas funds flowed into the region's stock markets amid investor optimism that regional economic growth will accelerate.

**Thai Baht and Singaporean Dollar Against the US Dollar**




*Note: Data are up to 23 Feb. 2006*
*Sources: The Federal Reserve Bank of New York*

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែមករា ថ្លៃអង្ករអន្តរជាតិកើនឡើង ថ្វីបើអង្ករបានពីការប្រមូលផលថ្មីនៅអាស៊ី បានមកដល់ទីផ្សារជាបន្តបន្ទាប់ក្តី ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) កើនដល់ ១១៨,៨ពិន្ទុ ធៀបនឹង ១១៦,៤ពិន្ទុ នៅខែធ្នូ ។ ថ្លៃអង្ករនៅ US នៅថេរត្រឹម ៣០៣ដុល្លារ/តោន ។ នៅថៃ ថ្លៃអង្ករកើន ៣,៩% ដោយសារប្រាក់បាតឡើងថ្លៃទល់នឹងដុល្លារ ។ នៅខែមករា អង្ករ Thai 100%B លក់ថ្លៃ ២៩៥ដុល្លារ/តោន ធៀបនឹង ២៩៤ដុល្លារ/តោននៅខែធ្នូ ២០០៥ ។

In January, world rice prices increased despite the continuous arrival of the new Asian harvest. The international price index (IPO) rose to 118.8 points, against 116.4 points in December. The rice prices in US held steady at US$303 per ton. In Thailand, prices increased by 3.9 percent due to the Bath's valuation against dollar. In January, the Thai 100%B was at US$295 per ton, up from US$284 per ton in December 2005.

**International Prices Index and Export Rice Prices** (US$/ton FOB)




Source: Osiriz/InfoArroz and InterRice.

នៅខែកុម្ភៈ សណ្តែកសៀង និងពោត បានឡើងថ្លៃ ។ សណ្តែកសៀងលក់បាន ២៣៧,០២ដុល្លារ/តោន ធៀបនឹង ២៣៣,៣៣ដុល្លារ/តោននៅខែមុន ហើយពោតលក់បាន ១០៧,៥៤ដុល្លារ/តោន ធៀបនឹង ១០២,៧១ ដុល្លារ/តោននៅខែមុន (ឡើងថ្លៃ ៥%) ។ នៅខែមករា ប្រេងឆាលក់ថ្លៃ ៤២៤ដុល្លារ/តោន ធៀបនឹង ៤២៩ដុល្លារ/តោននៅខែធ្នូ ។

In February, the price of soybeans and maize rose. Soybeans were sold at US$237.02 per ton, up from US$233.33 per ton in January. The price of maize increased by 5 percent from US$102.71 per ton to US$107.54 per ton in February. In January, palm oil was sold at US$424 per ton, down from US$429 per ton in December.

**International Prices of Soybean, Maize and Palm Oil** (US$/ton FOB)




Source: Food and Agriculture Organisation (FAO)

នៅខែកុម្ភៈ ប្រេងឆៅ និងសាំង បានចុះថ្លៃ ។ ថ្លៃលក់ដល់ដៃរបស់ប្រទេស OPEC នៅខែកុម្ភៈ គឺ ៥៨,២៣ដុល្លារ/ធុង រឺចុះថ្លៃ ២%ធៀបនឹងខែមុន ។ ថ្លៃសាំងធម្មតានៅ US Gulf Coast នៅខែកុម្ភៈ បានថយចុះដល់ ៤០,០៣ សេន/លីត្រ រឺចុះ ១២%ធៀបនឹងខែមករា (៤៥,៣៩សេន/លីត្រ) ។

In February, the prices of crude oil and gasoline decreased. The OPEC countries spot price of crude oil in February was US$ 58.23 per barrel, a 2 percent decline from the previous month. The conventional regular gasoline in US Gulf Coast in February fell by 12 percent from the previous month, selling at 40.03 cents per litre against 45.39 cents per litre in January.

**Prices of Crude Oil and Gasoline**




***Note: Data are up to 25 February** 2006*
*Sources: Energy Information Administration*

# ព័ត៌មានសេដ្ឋកិច្ច / Economic News

**ការចុះកិច្ចព្រមព្រៀងទូទាត់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនវៀតណាម-កម្ពុជា:** នៅថ្ងៃ១៥ កុម្ភៈ នៅភ្នំពេញ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង ធនាគារកសិកម្មនិងអភិវឌ្ឍន៍ជនបទវៀតណាម នឹងធនាគារអេស៊ីលីដា កម្ពុជា ដើម្បីសំរួលការទូទាត់ថ្លៃទំនិញឆ្លងកាត់ព្រំដែន និងផ្តល់សេវាហិរញ្ញវត្ថុដែល អាជីវករក្នុងប្រទេសទាំងពីរត្រូវការកាន់តែច្រើន ជាពិសេសក្នុងបណ្តាខេត្តជាប់ព្រំដែន ។ នាឱកាសនោះ លោកជំទាវនាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា បញ្ជាក់ថា កិច្ចព្រមព្រៀង គឺជាការចាប់ផ្តើមកិច្ចសហប្រតិបត្តិការច្រើនបែបយ៉ាងរវាងធនាគារទាំងពីរ និងរវាងប្រព័ន្ធធនាគារកម្ពុជា និងវៀតណាម ។

**កម្ពុជានឹងកសាងតំបន់សេដ្ឋកិច្ចពិសេសពីរថែមទៀត:** តំបន់សេដ្ឋកិច្ចពិសេសពីរទៀត នឹងត្រូវកសាងឡើងនៅក្រុងភ្នំពេញ និងខេត្តតាកែវ ។ ក្រុមហ៊ុននាំចេញ-នាំចូល Attwood គ្រោងវិនិយោគ ៦០លានដុល្លារ ធ្វើតំបន់សេដ្ឋកិច្ចពិសេសមួយលើដី ៣៥៣ហ.ត នៅជាយក្រុងភ្នំពេញ ដើម្បីទទួលផលិតករសំលៀកបំពាក់ ស្បែកជើង និងសំភារៈអគ្គីសនី ។ ក្រុមហ៊ុនអភិវឌ្ឍន៍ ដួង ជីវ នឹងអនុវត្តគំរោង ៧០លានដុល្លារ ដើម្បីកសាងតំបន់បែបនេះមួយលើដី ៥៧ហ.ត នៅស្រុកគីរីវង្ស ខេត្តតាកែវ ដើម្បីទាក់ទាញរោងចក្រកែច្នៃផលិតផលកសិកម្មដូចជា ត្រី និងស្រា ជាដើម។ ក្រុមហ៊ុនទាំងពីរនឹងចាប់ធ្វើសកម្មភាពពាណិជ្ជកម្មនៅចុងឆ្នាំនេះ ។ តាមការអនុមតិចុងក្រោយនេះ តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាកើនដល់ ៩ ដែលស្ថិតនៅក្រុងព្រះសីហនុ ខេត្តកោះកុង ស្វាយរៀង និង បន្ទាយមានជ័យ ។ រដ្ឋាភិបាលនឹងមានផ្តល់សេវាកម្មនៅតាមកន្លែងទាំងនេះ ហើយពុំមានយកពន្ធលើការនាំចូលវត្ថុធាតុដើមទេ ។ ឯកសារផ្សេងៗនឹងត្រូវពិនិត្យអនុម័តនៅទីនោះ គឺក្រុមហ៊ុននានាមិនបាច់មកទាក់ទងតាមក្រសួងជំនាញទេ ។

**កម្ពុជានឹងដាក់ប្រើប្រាស់ទំរង់គយតែមួយសំរាប់ការនាំចេញ-នាំចូល:** រដ្ឋាភិបាលកម្ពុជា គ្រោងដាក់ប្រើប្រាស់ទំរង់គយតែមួយសំរាប់ការនាំចេញ-នាំចូល នៅខែក្រោយ ដើម្បីកាត់បន្ថយការិយាធិបតេយ្យ និងអំពើពុករលួយ លើការនាំចេញ-នាំចូលទំនិញនៅកម្ពុជា ។ ទំរង់នេះ ដែលមន្ត្រីជំនាញបានពិនិត្យវិភាគជាមួយទីប្រឹក្សាធនាគារពិភពលោកនៅភ្នំពេញ នឹងត្រូវដាក់បញ្ចូលក្នុងប្រព័ន្ធច្រកចេញ-ចូលគយតែមួយកត់ត្រាតាមកុំព្យូទ័រ ដែលរដ្ឋាភិបាលគ្រោងអនុវត្តសាកល្បងនៅខែធ្នូ ។ ប្រព័ន្ធនេះ ដែលពួកទីប្រឹក្សាបញ្ជាក់ថា នឹងចុះកិច្ចសន្យាប្រគល់ទៅឱ្យក្រុមហ៊ុនចំរុះមួយជាមួយសហគ្រាសឯកជន នឹងរៀបចំឱ្យប្រើប្រព័ន្ធអ៊ិនធឺណិតផងដែរ ។ ពាណិជ្ជករអាចដាក់ជូនពិនិត្យនូវទំរង់តែមួយ ដោយបញ្ជូនវាទៅកុំព្យូទ័រធំមួយ (server) ដែលតភ្ជាប់នឹងក្រសួង-ស្ថាប័ននានាពាក់ព័ន្ធនឹងកិច្ចការជំនួញ ។ ប្រព័ន្ធនេះបានកសាងឡើង ដោយប្រើជំនួយរបស់អង្គការសហប្រជាជាតិ ។

***Vietnam-Cambodia cross-border trade payment agreement signed:*** A co-operation agreement between the Bank for Agriculture and Rural Development of Vietnam (BARD) and the ACLEDA Bank of Cambodia was signed in Phnom Penh on February 15. The agreement will facilitate cross-border trade payment services between Cambodia and Vietnam, catering to the ever-growing demand for financial services of the two countries' businesspeople and enterprises, especially in border provinces. Addressing the ceremony, Deputy Governor of the National Bank of Cambodia Nia Chathana said the agreement marks a start of the multi-faceted co-operation between the two banks and by extension, the banking systems of Cambodia and Vietnam. *(Cited from VNA 2/16/2006)*

***Cambodia to build two more special economic zones:*** Two more special economic zones will be built in Phnom Penh and Takeo province. The Attwood import-export company plans to invest US$60 million in a special economic zone on 353 hectares of land in the outskirts of Phnom Penh. The zone will house garment, footwear and electric appliance producers. The Doung Chhiv Development Company will implement a US$70-million project to construct a zone on 57 hectares of land in Takeo's Kirivong district, which plans to attract factories processing agriculture products such as fish and wine. The two firms will start their commercial activities by the end of this year. The latest economic zone-related government approval brings the number of Cambodia's economic zones to nine, some of them located in Sihanoukville, Koh Kong, Svang Rieng and Banteay Meanchey province. Government services are available on site in special economic zones, where no tax is imposed on imported raw materials. And all paperwork would be approved there so than companies do not need to come to the relevant ministries. *(Cited from Xinhua 2/16/2006)*

***Cambodia to introduce single import, export customs form:*** The Cambodian government plans to introduce a single customs form next month in order to reduce bureaucracy and opportunities for corruption in importing and exporting goods to and from Cambodia. The form, which was analyzed by officials at a meeting with World Bank consultants in Phnom Penh, will eventually be part of the computerized Single Window customs system, which the government plans to pilot-test by December. That system, which the consultants said could be outsourced in a joint venture with a private firm, could be structured using the Internet. Traders would be able to submit the single form by connecting to a server shared by the numerous ministries and agencies involved in trade. It is being developed with the aid of the United Nations. *(Cited from Xinhua 2/15/2006)*